**សាររបស់លោកអភិបាល អូលីវីយេ**
**ផ្ញើជូនបព្វជិតបព្វជីតាភូមិភាគភ្នំពេញ**
**ចំការទៀន ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២០**

សូមជម្រាបសួរ បងប្រុសបងស្រី លោកឪពុក ដែលជាបព្វជិតបព្វជីតានៅក្នុងភូមិភាគភ្នំពេញ។ ថ្ងៃនេះ ជាឱកាសមួយដើម្បីជួបជាមួយបងប្រុសបងស្រី និងលោកឪពុក យើងមិនបានជួបជុំគ្នាផ្ទាល់តាំងពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ ប៉ុន្តែយើងដឹងថាយើងបានជួបគ្នាតាមផ្លូវវិញ្ញាណជាច្រើនដងច្រើនសារ។ យើងបានជួបគ្នា ជួនកាលតាម YouTube ជួនកាលតាម Facebook និងជួនកាល WhatsApp ដែរ ដោយដឹងថានៅក្នុងភូមិភាគភ្នំពេញតែមួយ យើងជាអង្គតែមួយរួមជាមួយព្រះជាម្ចាស់ រួមជាមួយគ្រីស្តបរិស័ទ រួមជាមួយព្រះសហគមន៍របស់យើង និងរួមជាមួយសង្គមយើងផងដែរ។ បព្វជិតបព្វជីតានៅក្នុងភូមិភាគភ្នំពេញយើងមាន៣០ក្រុម ដែលសព្វថ្ងៃកំពុងបម្រើព្រះសហគមន៍ បម្រើសង្គមរបស់យើងនៅគ្រប់វិស័យជាពិសេស៖

**ទីមួយ អធិដ្ឋាន** ដើម្បីឲ្យភូមិភាគរបស់យើង ក៏ដូចជាប្រទេសកម្ពុជារបស់យើងពោរពេញដោយកម្លាំងដែលមកពីព្រះជាម្ចាស់។

**ទីពីរ នៅក្នុងវិស័យអប់រំ** យើងមានបងប្រុសបងស្រី លោកឪពុក ដែលមានសាលាមត្តេយ្យសិក្សា បឋមសិក្សា សាលាវិទ្យាល័យ សាលាបច្ចេកទេសវិជ្ជាជីវៈ សាលាអប់រំក្រៅប្រព័ន្ធ... ដើម្បីជួយទាំងកូនក្មេង ទាំងយុវជនយុវនារីអាចទទួលបានការអប់រំដើម្បីរៀបចំអនាគត និងដើម្បីមានជីវិតដែលធ្វើដំណើរយ៉ាងច្បាស់លាស់នៅក្នុងសង្គម។ យើងមានបងប្រុសបងស្រី លោកឪពុកដែលរស់នៅក្នុងគ្រប់កាលៈទេសៈនៃជីវិតរបស់បងប្អូនយើង ជាពិសេសអ្នកតូចតាច ជនពិការអ្នកក្រីក្រ ស្ត្រីកម្សត់ទុគិត ស្ត្រីពេស្យាចារ អ្នកដែលជាប់នៅមន្ទីរឃុំឃាំង បងប្អូនដែលមានមេរោគអេដស៍ ដូចជាអ្នកជំងឺនានា យើងនៅគ្រប់វិស័យនៅក្នុងសង្គម។ ប្រហែលសង្គមបច្ចុប្បន្ននេះ អត់សូវចាប់អារម្មណ៍ជាមួយបងប្អូនតូចតាច ប៉ុន្តែយើងដឹងថាយើងមានបងស្រី យើងមានបងប្រុសយើងមានលោកឪពុក ដែលមានវត្តមាននៃសេចក្តីស្រឡាញ់មកពីព្រះជាម្ចាស់ និងណែនាំឲ្យបងប្អូនទាំងនោះយល់ថាជីវិតគេមានតម្លៃ ជីវិតគេមានអត្ថន័យ និងធ្វើដំណើរនៅលើពិភពលោកនេះតទៅទៀត អាចធ្វើនេះបានដោយសារវត្តមានរបស់បងប្រុសបងស្រី ជាកម្លាំងកាយកម្លាំងចិត្តសម្រាប់ពួកគាត់។

ដូច្នេះ នៅពេលនេះខ្ញុំសូមថ្លែងអំណរគុណដល់បងប្រុសបងស្រី លោកឪពុក ជាបព្វជិតបព្វជីតា សម្រាប់ការបម្រើ ការយកចិត្តទុកដាក់ប្រកាសដំណឹងល្អ នៅក្នុងសង្គមបច្ចុប្បន្ននេះ ជា

អត្ថន័យមួយយ៉ាងពិសេស។ នៅក្នុងកូវីដ១៩នេះ ខ្ញុំជឿថាវត្តមានរបស់បងប្រុសបងស្រីជាកម្លាំងមួយសម្រាប់ពួកគាត់ និងសម្រាប់ព្រះសហគមន៍របស់យើងដែរ។ ខ្ញុំសូមថ្លែងអំណរគុណម្តងទៀតសម្រាប់ការតស៊ូ តាំងពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ ដែលយើងមិនអាចជួបជុំគ្នាបាន ខ្ញុំដឹងថាបងប្រុសបងស្រីមួយចំនួនអត់មានអភិបូជាជាប្រចាំរយៈពេលយូរដែរ។ ពីរដូវបុណ្យចម្លងយើងចែកព្រះកាយព្រះគ្រីស្ត សព្វថ្ងៃបន្តិចម្តងៗយើងមានលោកឪពុកដែលថ្វាយអភិបូជាតាមកាលវិភាគដូចពីមុន និងយើងមានលោកឪពុកមួយចំនួនដែលទៅផ្ទះតាមក្រុមតូចៗ បងស្រីក្រុមតូចៗក៏អាចចូលរួមនៅក្នុងអភិបូជានោះបានដែរ។

នៅពេលនេះ ខ្ញុំចង់ជំរុញឱ្យយើងជាបព្វជិតបព្វជីតានៅក្នុងភូមិភាគភ្នំពេញ ដើម្បីបន្តដូចនៅក្នុងសម័យគ្រីស្តបរិស័ទពីដើម (សម័យកិច្ចការគ្រីស្តទូត) នៅពេលនោះគ្រីស្តបរិស័ទព្យាយាមអធិដ្ឋាន។ វត្តមានរបស់បងប្រុសបងស្រីដែលអធិដ្ឋានជាប្រចាំ បងស្រីកាមែលដែលជាបងស្រីសម្ងាត់បានអធិដ្ឋានច្រើនណាស់។ នេះជាកម្លាំងមួយសម្រាប់ភូមិភាគយើងទាំងមូល ជាកម្លាំងមួយដែលយើងមើលមិនឃើញ ប៉ុន្តែយើងដឹងថាការអធិដ្ឋានណែនាំឱ្យផ្លូវវិញ្ញាណរបស់ភូមិភាគទាំងមូលអាចទៅមុខ និងរកឃើញប្រភពនៅក្នុងព្រះយេស៊ូដែលជាផ្លូវ ដែលជាសេចក្តីពិត ដែលជាជីវិត។

ពីដើមគ្រីស្តបរិស័ទ ព្យាយាមស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ យើងមានបងប្រុសបងស្រីមួយចំនួនដែលធ្វើការតាមព្រះសហគមន៍ ភ្ជាប់ជាមួយគ្រីស្តបរិស័ទ ភ្ជាប់ជាមួយជំហានទីពីរ ភ្ជាប់ជាមួយបងប្អូនដែលទទួលការអប់រំជំនឿ។ ដូច្នេះ យើងបន្តរកមធ្យោបាយដើម្បីមានទំនាក់ទំនង ដើម្បីលើកទឹកចិត្ត ដើម្បីផ្ញើព្រះបន្ទូល ដើម្បីឱ្យបន្ទូលរបស់ព្រះជាម្ចាស់បន្តណែនាំជីវិតគ្រីស្តបរិស័ទរបស់យើង ដែលអត់មានឱកាសចូលក្នុងព្រះវិហារ ឬអត់មានឱកាសទទួលអប់រំជំនឿដូចពីមុនដែរ។ គ្រីស្តបរិស័ទពីដើម ព្យាយាមសម្តែងធម៌មេត្តាករុណា ដើម្បីចែកសេចក្តីស្រឡាញ់ដល់ស្ត្រីមេម៉ាយ ដល់អ្នកជំងឺ ដល់កុមារកំព្រា។ ដូច្នេះ បងប្រុសបងស្រីដែលធ្វើការនៅគ្រប់វិស័យដូចខ្ញុំបានរំឭកមុននេះ ខ្ញុំសូមថ្លែងអំណរគុណម្តងទៀត និងសូមព្រះជាម្ចាស់ប្រទានពរ ដើម្បីមានកម្លាំងបន្តបម្រើនៅក្នុងបរិយាកាសប្លែកនេះ ដោយដឹងថាមុនកូវីដ១៩ យើងមានបងប្អូនដែលខ្វះខាត ខ្វះសេចក្តីស្រឡាញ់ ខ្វះការលើកទឹកចិត្ត ខ្វះកម្លាំងកាយកម្លាំងចិត្តយ៉ាងច្រើនដែលយើងបានចាប់ផ្តើមជួយហើយ។ ប៉ុន្តែ នៅក្នុងកូវីដ១៩នេះនិងនៅក្នុងប៉ុន្មានខែខាងមុខនេះយើងជឿថាឥទ្ធិពលនៃកូវីដ១៩ប្រហែលណែនាំឱ្យប្រជាជនបាត់បង់សេចក្តីសង្ឃឹមថែមទៀត ដោយសារអស់ការងារធ្វើ អស់ចំណូលប្រចាំខែ ខ្វះម្ហូបអាហារ ឬការសិក្សាសម្រាប់កូនៗ ឬសុខភាពជាប្រចាំ។ ខ្ញុំសង្ឃឹមថា យើងជាបព្វជិតបព្វជីតាភូមិភាគភ្នំពេញ យើងសហការគ្នាសម្រុះសម្រួលបញ្ហាមួយ

ចំនួន ដើម្បីឱ្យកន្លែងដែលយើងនៅយើងអាចមើលឃើញ អំណរសប្បាយដែលមកពីព្រះជាម្ចាស់ យើងមើលឃើញបងប្អូនដែលឈឺចាប់ ដែលពិបាកចិត្ត ឲ្យគេអាចរកឃើញសេចក្តីសង្ឃឹមវិញ ដើម្បីធ្វើដំណើរទៅមុខបាន។

ដូច្នេះ នៅពេលនេះខ្ញុំសូមឱ្យយើងទាំងអស់គ្នាជាបព្វជិតបព្វជីតាបន្តអធិដ្ឋាន ពីថ្ងៃអាទិត្យ យើងបានអធិដ្ឋានសម្រាប់ការត្រាស់ហៅ ថ្ងៃព្រហស្បតិ៍ស្អែកនេះជាការអធិដ្ឋានប្រចាំសម្រាប់ការត្រាស់ហៅដែលយើងមានរៀងរាល់ខែ។ នៅពេលនោះ ខ្ញុំសូមឱ្យក្រុមបព្វជិតបព្វជីតាមួយចំនួនចូលរួមអធិដ្ឋាននៅក្នុងមួយម៉ោងកន្លះៗ ខ្ញុំនឹងធ្វើកាលវិភាគដើម្បីអធិដ្ឋានសម្រាប់ពិភពលោកផង អធិដ្ឋានសម្រាប់ព្រះសហគមន៍យើងផង សង្គមយើងផង យុវជនយុវនារីផង។ នៅក្នុងទាំង៣០ក្រុម យើងមានតែមួយក្រុមដែលបានកើតលើទឹកដីកម្ពុជា គឺក្រុមបម្រើព្រះយេស៊ូ (បងស្រីសុភីដែលសព្វថ្ងៃមានតែម្នាក់ឯង)។ ជាពេលវេលាមួយ ដើម្បីអធិដ្ឋានថែមទៀតឱ្យយើងមានបងប្រុសបងស្រីខ្មែរយ៉ាងច្រើននៅក្នុងក្រុមយើង និងមានក្រុមបព្វជិតបព្វជីតាថ្មីៗដែលចេញពីទឹកដីរបស់យើង ដើម្បីបម្រើបងប្អូនរបស់យើងនៅប្រទេសកម្ពុជា។ យើងមានបងប្រុសបងស្រី នៅក្នុងភូមិភាគភ្នំពេញជាង១៥០នាក់មកពីប្រទេសជាច្រើន។ ខ្ញុំមិនភ្លេចអធិដ្ឋាន សម្រាប់ប្រទេសកំណើតរបស់បងប្រុសបងស្រី សម្រាប់ក្រុមគ្រួសារ សម្រាប់បងប្អូនដែលមានទុក្ខលំបាក ដោយដឹងថាយើងជាមហាគ្រួសារតែមួយនៅក្នុងភូមិភាគភ្នំពេញ។ វត្តមានរបស់បងប្រុសបងស្រីដែលមកពីប្រទេសនានា ណែនាំឲ្យយើងចូលនៅក្នុងរបៀបប្លែក និងជិតស្និទ្ធបំផុតជាមួយប្រទេសមួយចំនួនដែលកំពុងជួបទុក្ខលំបាកយ៉ាងខ្លាំងដោយសារជំងឺកូវីដ១៩។ អាម៉ែន៕